**អតីតបើមានកម្មមកជាមួយវ៉ានៅតែអន្ទោល**

«យប់មិញខ្ញុំស្រមៃភ្នែកស្រស់ ឃើញមនុស្សស្រីម្នាក់អង្គុយលើគ្រែរបស់ខ្ញុំ! ស្រែកឡើងបងដេវីដខឹង!»

ធីតាអង្គុយញ៉ាំបាយសាច់គោងៀតដែលអ្នកបម្រើផ្ទះនេះធ្វើទទួលភ្ញៀវភ្នំពេញ។ អ៊ំអ៊ីនជាអ្នកចាស់ទុំមេផ្ទះរបស់ប៉ាម៉ាក់គន្ធានៅតែតាមមកនៅជាមួយទោះគន្ធារៀបការហើយក៏ដោយ។

«ក្មួយគន្ធា ហត់ពេកដឹង? ពិសាឱ្យច្រើនទៅ ងៀតនេះក្មួយចូលចិត្ត!»

គន្ធាតវ៉ាខណៈដាណោចុចទូរសព្ទផងធ្វើមុខសើចចំអន់ផង។

«ខ្ញុំឃើញមែន មិនមែនលេងសើចទេអ៊ំ! រូបមនុស្សស្រីចំណាស់!»

«តែ.....លោកក្មួយដេវីដថាមិនឃើញអីទាំងអស់!»

គន្ធាងាកទៅសម្លក់ប្ដីដែលកំពុងអុចធូបថ្វាយព្រះភូមិនៅខាងក្រៅផ្ទះ។

«ខ្ញុំឆ្ងល់រឿងប៉ុដេវីដហ្នឹងទៀត! និយាយគ្នារឿងអាមុំមិនទាន់ស្អីផង ក៏ស្រម៉ុកខុល មិនដឹងពុតឬមែនទេ!»

ឃើញចៅហ្វាយតូចមិនសប្បាយចិត្តនឹងគ្នា អ៊ំអ៊ីនរកផ្លូវដកថយ។

«អ៊ីចឹងអ៊ំទៅចិតក្រូចសិន!»

«អត់មានកាហ្វេទេអ៊ំ? ក្រូចរហូតហើយនៀក!» ដាណោរអ៊ូ។

«មានកូនស្រី ចាំអ៊ំឆុង!»

«ទៅឆុងទៅអ៊ំ! គន្ធាចាំខ្ញុំលួង! ឆុងឱ្យចាស់ណ៎ាអ៊ំ ហើយអត់ដាក់ស្ករទេ!»

ធីតាងាកមកញញឹមលេបខាយ៖

«ស្ទីលគេCEO ញ៉ាំឡើងអាមេរិកខេណ្ឌ!»

«ឡូយអ៊ីចឹង!»

ស្រាប់តែគន្ធាទាញពីរនាក់នេះកេះខ្សឹប៖

«នែ៎ មានរឿងមួយចង់ពិគ្រោះពួកឯង! ពេញមួយយប់.....ខ្ញុំ......ដេកមិនលក់សោះ!»

ធីតាដកដង្ហើមធំ។ ដាណោវិញលបមើលទៅប្ដីគន្ធាដែលដើរចុះឡើងនៅសួន។ ឆ្លៀតពេលនេះក៏ខ្សឹបសួរវិញ៖

«ល្អហើយ ប្ដីឯងចេះគិតណាស់មិនចូលមកវំខានយើងជជែកគ្នាទេ! ប្រាប់មកឯងកើតស្អីឯងនាងគន្ធា?»

«មនុស្សអង្គុយចុងជើងគ្នាយប់មិញ រូបរាងមើលពីក្រៅមួយឆ្វាច់....ដូច.....ជា...យាយ.....នួន យាយនួនបេះបិទ!»

ប្រាវ.....ធីតារបូតដៃកាន់សមស្លាបព្រា ដែលបម្រុងចាប់គោរងៀត។

ចំណែកដាណេឯណេះ គាំងសម្លឹងគន្ធា។

ពួកគេស្លេក។

គន្ធាងក់ក្បាលៈ

«អញនិយាយមែន!»

ធីតាយកកែងដៃកេះគន្ធាៈ

«កុំនិយាយទៀត! ទោះមែនក៏ដោយ! អញអត់ចង់ដឹង អត់ចង់ឮ»

យាយអ៊ីនវិញ ឈរក្បែរម៉ាស៊ីនឆុងកាហ្វេ ងាកមកពីចង្ក្រានដោយទឹកមុខចម្លែក។ គាត់ស្ដាប់ឮទាំងអស់ ព្រោះគាត់ចង់ដឹងថាពួកគេនេះមានរឿងអ្វីនឹងគ្នា ព្រោះចាប់តាំងពីមានមិត្តមកលេងស្រាប់តែយប់មិញ គន្ធាស្រែកមមើបែកផ្ទះ។ សភាពខ្សឹបខ្សៀវដំណាក់កាលនេះ អ្នកបម្រើចំណាស់អាចកាត់យល់បានថា អ្នកទាំងបីនេះ ដឹងថាមានរឿងអ្វីចំពោះយាយនួន បានជាសម្ដីគន្ធាខ្លីៗធ្វើឱ្យពួកគេភ័យ។

អ្នកបម្រើប្រញាប់ដើរចេញទៅចុចទូរសព្ទរកឪពុកម្ដាយគន្ធាហើយសួរៈ

«ថៅកែ? យាយនួនជាអ្នកណា?»

**យប់មួយកាលពីប្រាំឆ្នាំមុន**......

«នែ ឃ្មុំ? ហើយ....ទៅលបលាក់មើលកុនជាមួយម្នាក់មកពីកំពង់សោមនោះហ្មែន?» ធីតាមកកាត់មុខស្រីមុំហើយសួររវែកញែក។

«ត្រូវហើយ....ដោយសារ.....!»

«មិនបាច់ដោះស្រាយទេ! ចរិតអន់! កុំមកហៅយើងថាមិត្ត បានស្ទីលាក់គ្នា ដើរចូលនាំតែខូចឈ្មោះជាមួយស្រីនឹងលើអង្កើរក្រោមធុនឯងទេ!» គន្ធានិយាយកាត់ព្រោះផ្ទុះកំហឹងច្រណែន។

«ត្រូវហើយ នាំតែខូចស្អុយមួយ ស្អុយដោយម៉ាកន្រ្គកដោយសារវា!» ដាណេជំរុញបន្ថែមដាក់គន្ធាដែលកំពុងប្រចណ្ឌ។

«ខ្ញុំថាចង់ប្រាប់ពួកឯងដែរតែមិនទាន់ដល់ពេល!» ស្រីមុំដឹងថាគេខឹងក៏ខំអង្វរមិត្ត តែធីតានៅតែចាក់

សាំងបន្ថែមលើភ្លើង៖

«ឈប់រាប់អានវាទៅ! មនុស្សដូចវាជាមនុស្សស៊ីក្បាលមិត្តភក្តិ!»

«ខ្ញុំ....តែ.....ទៅមែន ត្រឹមមើលកុនទេ គ្មានបានធ្វើអីខុសទេ!»

ស្រីមុំខំតវ៉ាធ្វើឱ្យគន្ធាជ្រួញចិញ្ចើមក្រម៉ូវ ព្រោះអ្នកដែលប៉ងថាបានទៅមើលកុនរ៉ូមែនទិកពីរនាក់ដេវីដគួរតែជាខ្លួន ដែលមានសិទ្ធិជាងគេ ជាមេដឹកនាំក្រុមរហូតមកមិននឹកថាមកចាញ់ចិត្តក្រមុំស្រុកកំរៀងសោះ។

«ហើយ....ទទួលស្រឡាញ់គេហើយមែនទេ?» ដាណេខំបង្ករឿងឱ្យផ្ទុះឡើងព្រោះគំនិតប្រៀបធៀបច្រណែនដដែលនេះ។

«ឈប់ឱ្យខ្ញុំឃើញមុខឯងទៀត!» គន្ធាថាហើយចាកចេញខឹងខ្លាំង។ តាមពិតគន្ធាទេ ដែលចង់បានដេវីដ មិនសមណាកូនប្រុសអ្នកមាន មិនស្មានយល់បានពីចិត្តអ្នកមានដូចគ្នា ប៉ុន្តែបែរជាណាត់ស្រីមុំ។

«ហើយមិនទាន់ចប់ទេ យើងនឹងទៅប្រាប់ម្ដាយឯង ពេលយើងទៅបាត់ដំបង!»

ដាណេឆ្លៀតថែមមួយម៉ាត់នេះធ្វើឱ្យស្រីមុំក៏ស្ទុះទៅតាមពីក្រោយ....៖

«នែ៎ មិនរាប់គ្នាទៀតក៏បាន តែស្នេហាជារឿងរបស់គ្នា ពួកឯងម៉េចក៏មកព្រួតធ្វើមារចឹង?»

សម្ដីតវ៉ារបស់ស្រីមុំ រឹតតែគុណទ្វេនូវភាពមួម៉ៅក្ដៅចិត្តរបស់ពួកគេ។ គន្ធាងាកមកច្រានស្រីមុំមួយទំហឹង ដួលផ្ងារក្រោយទៅលើដី។

«ស្រីមុខក្រាស់ហ៊ាននិយាយពាក្យករីទៀតនាងល្អ?»

ពីរបីដង្ហើមផុតទៅ នៅមិនឃើញស្រីមុំបើកភ្នែក ពួកគេទាំងបីក៏ឈប់ជេរ ហើយមើលមុខគ្នាដោយសង្ស័យ។

«ស្អី? ច្រានប៉ុណ្ណឹងធ្វើក្រោកលែងរួច?» គន្ធាខាំមាត់គិតថាមុំរំអួយ។

ភ្លាមនោះធីតារត់ថយក្រោយមកឱបដាណេ។ មិត្តទាំងបីឈរមើលស្រមោលស្រីមុំដែលប្រកាច់នៅលើឥដ្ឋ។

គិតភ្លាមៗថា នាងច្បាស់ជាដួលជុងនឹងអ្វីមួយមិនខាន។

ពិតណាស់! ស្រមោលឈាមចាប់ផ្ដើមដាមរត់មករវាសពេញឥដ្ឋ។

គន្ធាទម្លាក់ដៃដែលក្រពាត់ព្រោះមិននឹកស្មានថា រឿងក្លាយជាធំ។

«នែ ឃុំ! កុំធ្វើពុតវ៉ី!»

គន្ធានិយាយទាំងភ័យញ័រជាការដឹងខ្លួនហើយថាស្រីមុំរបួសធ្ងន់ខ្លាំង។

ដាណេនិយាយញ័រមាត់៖

«វាធ្វើពុតអីទៀត? ឯងមិនឃើញក្បាលវាមុតដែកទេ?»

«ទេ! យើងមិនដឹង!!!! អ្នកណាដឹងថាមានដែកនៅហ្នឹង? ហើយសុខៗវារត់មកតោងអញធ្វើអី?»

ស្កន់ជាន់លើស្លន់ ស្រមោលយាយចាស់ម្នាក់បង្ហាញមកដល់។

«ស្លាប់ៗហើយ ពួកឯង.....ពួកឯងព្រួតគ្នាធ្វើអីចៅខ្ញុំហ្នឹង?»

គាត់គឺជាស្ត្រីចំណាស់ម្នាក់អង្គុយលើកៅអីពិការ។

ទាំងបីអ្នកមិនដែលដឹងថាស្រីមុំមានយាយម្នាក់នៅទីនេះជាមួយនោះទេ។ ងាកមកមើលឈាមរហាចនៅលើដីពួកគេនឹងត្រូវមានទោសពីបទសម្លាប់មនុស្ស មិនតែប៉ុណ្ណោះមានអ្នកមកតាមទៀត។

«វរហើយ! ឯងនឹងជាប់គុក!» ធីតាកេះគន្ធា។

«បើយើងជាប់ពីរនាក់ឯងក៏ជាប់!» គន្ធាសម្លុតព្រោះស្លន់។

យាយរុញរទេះមកក្បែរចៅស្រែកសង្វេគយំសោក។

«ពុទ្ធោ ស្រីមុំ? យាយមិនសុខចិត្តទេ ជួយផង!!!»

ដូច្នេះហើយគន្ធាងាកមកសម្លឹងធីតានិងដាណេដែលកំពុងភ័យរន្ធត់ខ្លាចមានគេមកឃើញច្រើនគ្នា។

នាងមានស្មារតីខ្លាំងជាងគេ ហើយនាងក៏ដឹងថាបើសមត្ថកិច្ចមកដល់ ពួកគេនឹងចង្អុលមកនាង។ ដោយមិនគិតយូរព្រោះយាយរឹតតែស្រែកទ្រហោយំខ្លាំងឡើង គន្ធាចាប់ផ្ដើមដើរទៅក្បែរយាយហើយរុញរទេះនេះសំដៅទៅមាត់បឹង។

ធីតានិងដាណេគាំង....ចំហមាត់ ប៉ុន្តែគ្មានអ្នកណាព្រមឃាត់ឬធ្វើអ្វីម្យ៉ាងទេ។

សំឡេងយាយចាស់បានស្រែកដាក់ពាក្យទំនាយ....៖

«ឯងធ្វើបាបចៅយើង! ពួកឯងនឹងរស់នៅយ៉ាងវេទនាដើម្បីសងបំណុលកម្មម្ដងបន្តិចម្ដងបន្តិចរហូតដល់អស់អ្វីអាចសងបាន!»

ទំនាយកណ្ដាលយប់កាន់តែគួរឱ្យរន្ធត់ ដោយមិនចង់ស្ដាប់តទៅទៀត ធីតារត់ទៅដល់ហើយជួយរុញគន្ធាទម្លាក់យាយទៅក្នុងទឹកប្រុង។

គ្មានអ្នកណាដឹងថា ហេតុអីបានជាយាយចាស់មកពីកំរៀងត្រូវលង់ទឹកស្លាប់ពេលមកស្នាក់

ភ្នំពេញឱ្យចៅស្រីនាំទៅពេទ្យមើលជើងសោះទេ។

ចំណែកចៅស្រី ប៉ូលិសក៏មិនអាចសួរនាំព្រឹត្តិការណ៍ ព្រោះនាងត្រូវរងរបួសលែងដឹងអ្វី ចាប់ពីពេលនោះមកគឺ អាចត្រឹមនៅអង្គុយលើរទេះស្មៀមមួយកន្លែង។

ការព្យាបាលច្រើនឆ្នាំមកនេះបានត្រឹមបើកភ្នែកនិងលេបអាហារដែលម្ដាយបញ្ចុក តែស្រីមុំមិនមែនជាស្រីមុំដូចពីមុនទៀតនោះទេ នាងលែងនិយាយបាន លែងឮ លែងឆ្លើយតបអ្វីកើត។

**សំឡេងទូរសព្ទកណ្ដាលអធ្រាត្រ**

«ម៉េចក៏លុយខែនេះតិចជាងខែមុន?» អ្នកដែលខលមកជាស្ត្រីចំណាស់ម្នាក់។

«មីងដោយសារខ្ញុំមានវិបត្តិហិរញ្ញវត្ថុ មីងក៏ដឹងដែរ ចាំខែក្រោយខ្ញុំឱ្យទៀត!»

«មិនបាន! នាងមានដីចម្ការនិងហាងត្បូងច្រើនកន្លែងឆាប់លក់មកឱ្យខ្ញុំបើមិនចង់មានរឿង!»

គន្ធាស្រែកឡូឡា៖

«ហួសហេតុពេកហើយមីង! អ្នកណាលក់ហាងឱ្យមីងឯង? ស្មានថាហាងរបស់ខ្ញុំ?!»

«អឺ មិនឱ្យ? ចាំទេ? កាលណោះអ្នកណាជួយបន្លំលិខិត ជាអក្សរស្រីមុំដើម្បីឱ្យឯងបានរៀបការជាមួយដេវីដ?»

គន្ធាញាក់ញ័រព្រោះមានអាថ៌កំបាំងអតីតកាលក្នុងដៃស្ត្រីចំណាស់ម្នាក់ជាអតីតគ្រូរបស់ស្រីមុំអាចកាទ្បែអក្សរដូចស្រីមុំបេះបិទបាន។ កាលណោះព្រោះចង់រៀបការជាមួយដេវីដក៏ឱ្យគាត់ជួយក្លែងសំបុត្រពីស្រីមុំថា នាងមិនមានជំនឿថាជំងឺក្បាលអាចជាទេ បើស្រឡាញ់នាងដេវីដត្រូវសន្យាថានឹងរៀបការជាមួយគន្ធាមិត្តរបស់នាង។

«ខ្ញុំឱ្យលុយមីងរហូតមក ច្រើនឆ្នាំនេះ វាល្មមមីងគ្រប់គ្រាន់ហើយ! ឈប់ជម្រិត ឈប់គំរាមខ្ញុំ! រឿងកន្លងយូរហើយ ទោះមីងនិយាយអ្វីក៏គ្មានអ្នកណាជឿទៀតដែរ! ស្មានថា ប្ដីខ្ញុំលែងខ្ញុំជឿមីងឯង? ខ្ញុំធុញណាស់!»

ស្រមោលអ្នកណាម្នាក់បង្ហាញនៅមាត់ទ្វារ។

គន្ធាមានអារម្មណ៍ថាជាដេវីដក៏ ស្រែកវ៉ាសៗប៉ះទម្លាក់ទូរសព្ទរបូតចោលដោយក្ដីតក់ស្លុត តែបែរមកវិញ មិនមែនជាប្ដីរបស់នាងនោះទេ។ គ្មានអ្នកណានៅកន្លែងនោះសោះ។

ដេវីដរបស់នាងទើបតែរត់ឡើងមកពីក្រោម។

«មានរឿងអ្វី?»

«ស្រវាំងភ្នែកឃើញបងឯងមកឈរពីក្រោយ!»

ប្ដីហួសចិត្ត ធ្វើមុខធុញទ្រាន់។

«មួយរយៈនេះ អូនឧស្សាហ៍ឃើញអីប្លែកៗណាស់! គេងឱ្យគ្រប់បន្តិចទៅ! ហើយរឿងពួកម៉ាកពពាក់ពពូនមកលេងហ្នឹង បើនាំរឿងខ្លាចៗមកនិយាយ បងមិនចង់ឃើញពួកគេទៀតទេ!»

ប្ដីដើរចោលទៅក្រៅបាត់បន្សល់នូវគន្ធាអង្គុយលើពូកមិនសប្បាយចិត្តម្នាក់ឯង។ ពេលខ្លះយល់ថាដេវីដនិយាយត្រូវ។ ប្រសិនបើធីតាមិនមកលេងទេ ក៏ប្រហែលនាងបានសុខជាងនេះដែរ។

**ពាក្យទំនាយ**....

ស្អែកឡើង....

«គន្ធាយើងគិតទៅវត្ត ឱ្យលោកស្រោចទឹកម្ដងឬក៏យ៉ាងម៉េច?»

គន្ធាដកដង្ហើមធំ៖

«មួយរយៈនេះគ្នារវល់ទៅប៉ៃលិនជាមួយប្ដីគ្នារកទិញដី!»

ពួកគេមើលមុខគ្នា ធីតាធ្វើមុខស្មើសួរបញ្ជាក់៖

«ចង់និយាយហ្នឹង ឱ្យយើងឈប់នៅស្នាក់មែនទេ? ម៉េចមិនថាចំៗមក!»

គន្ធាឈ្លីក្បាល។

«យប់មិញខ្ញុំយល់សប្ដិមិនល្អទេ! មុនគេងឈ្លោះជាមួយដេវីដទៀត គ្នាឃើញរឿងមិនពិតជាបន្តបន្ទាប់!»

ធីតាភ្ញាក់របូតកាហ្វេពីដៃ ព្រោះកាលដែលពួមិត្តនាងនិយាយបែបនេះ ចួនគ្នាណាស់នឹងអ្វីដែលជាហេតុផលឱ្យធីតារត់ពីភ្នំពេញមកបាត់ដំបង។

«ខ្ញុំក៏អ៊ីចឹងដែរ!» ដាណេជ្រប់មុខនិយាយស្រងូត។

ធីតាដកដង្ហើមធំ៖

«លាក់ពួកឯងដល់ណ៎ា គ្នាមកបាត់ដំបងនេះ ព្រោះថា.....ចង់...ចង់រកដំណោះស្រាយ! ដឹងទេ....កាលនៅភ្នំពេញ នៅមិនបាន ដេកពួនមិនកើត យល់សប្ដិឃើញ តែ....នាងឃុំ.....និងយាយជិះរទេះហ្នឹង!»

គន្ធាពួមិត្តសារភាពហើយកាន់តែផ្អែកស្មារអស់សង្ឃឹម។

ពួកគេបានសម្រេចចិត្តនាំគ្នាទៅស្រោចទឹកនៅវត្តដំរីស។ បានឱ្យលោកជួយស្រោចទឹកសូត្រមន្តរំដោះគ្រោះហើយ នៅមិនស្រឡះអ្វីជាដុំកំភួន នាំគ្នាត្រសងចេញដើរមកឡាន ភ្លាមនោះប្រទះយាយ

ចាស់ម្នាក់ស្លៀកសពាក់សបង្ហាញខ្លួន។

«ក្មួយស្រីទាំងបីចង់មើលជតារាសីទេ!»

យើញមនុស្សចាស់ គន្ធាមានអារម្មណ៍ធុញ ព្រោះនឹកឃើញ.....

«ខ្ញុំមិនត្រូវការមើលអីទេ!»

ចុចឡានបើកទ្វារ ស្រាប់តែឃើញដាណេស្ទុះទៅរកយាយនោះ....

«ខ្ញុំ....ខ្ញុំចង់....មើល!»

ធីតាងាកមកទាំងចំហមាត់ឆ្ងល់ដែលដាណេស្រាប់តែស្ងាត់ៗបែរជាស្លន់ជាងគេ។

«ខ្ញុំមិនត្រូវការមើលអីទេ ខ្ញុំទើបតែស្រោចទឹករួច! តោះ នាងខ្មៅ!»

ធីតាទាញដៃដាយអាវតែដាណេទម្លាក់ តែមិត្តនៅតែឈរផ្ទឹងដូចមនុស្សគ្មានអារម្មណ៍។

«យី មីនេះ!»

គន្ធាសម្លក់និងជេរដាណេ ធ្វើឱ្យយាយចាស់និយាយប្រាប់ឡើង៖

«ការស្រោចទឹក មិនអាចជួយបណ្ដេញកម្មដែលបានធ្វើដោយបង្ហូរឈាមបានទេ!»

ពួកគេផ្លាស់ទឹកមុខ ងាកមកមើលម្ចាស់សម្ដីរួចមើលមុខគ្នា។ មានតែពួកគេបីនាក់ដែលដឹងថាលោកយាយកំពុងនិយាយចំបេះបិទដូចរឿងអតីតរបស់ពួកគេ។

ដាណេស្លន់លើសដើម ដូចលែងគ្រប់គ្រងអារម្មណ៍ភ័យខ្លាចបាន ក៏ស្ទុះចូលទៅខ្សឹបយាយ៖

«យាយ ខ្ញុំយប់មិញយល់សប្ដិចង្រៃណាស់ ថាមានសត្វឆ្មាមកខាំជើងខ្ញុំនិងគន្ធា! វាខាំយើងទាំងពីររហូតដល់ស្លាប់លែងកម្រើកបាន!»

គន្ធានឹកឃើញភ្លាមរឿងឃើញប្ដីមកឈរពីក្រោយធ្វើទឹកមុខដូចបិសាច។

«ចាំយាយគន់គូរគ្រោះឱ្យ! ក្រែងអាចជួយទាន់!»

«ម៉េចដឹងពួកខ្ញុំមានគ្រោះ?»

គាត់ញញឹមមិនមាត់។ ដោយគិតគ្នាបានបន្តិច ចុងក្រោយពួកគេបានសម្រេចចិត្តនាំគ្នាធ្វើដំណើរទៅតាមគាត់ដល់ខ្ទមតូចមួយក្បែររបងវត្ត។

ដោយទ័លច្រកហើយ ក៏ព្រមឱ្យគាត់មើលបាតដៃនិងបុគ្គលិកលក្ខណៈខែឆ្នាំ។

បានបន្តិចយាយចម្លែកបាននិយាយប្រាប់ ៖

«ដល់ពេលដែលពាក្យទំនាយ មកតាមទារបំណុលកម្មហើយ!»